# តារាងលំហូរនៃនីតិវិធីលែងលះ

បានចុះបញ្ជីអាពាហ៍ពិពាហ៍

YES

ភាគីទាំងពីរបានព្រមព្រៀងលែងលះគ្នា

YES

មានកូនដែលជាអនីតិជន

YES

បានកំណត់អំពីអ្នកមានអំណាចមេបា

YES

"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (ដីកាសម្រេច)"

ពាក្យសុំលែងលះដោយការព្រមព្រៀងផ្អែកតាមបញ្ញត្តិនៃមាត្រា ៩៧៩ នៃក្រមរ/ដ (មាត្រា ៣ និង ចំណុច ៥ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធនៃ**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**)

NO

"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (សាលក្រម)"

បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃចំណុច ង កថា/ទី ១ មាត្រា ៩៧៨ នៃក្រមរ/ដ (ចំណុច គ មាត្រា ៣ និង កថា/ទី ១ មាត្រា ២២ នៃ**ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** )

NO

"បើមានតែការលែងលះគ្នា (ដីកាសម្រេច)"

ពាក្យសុំលែងលះដោយការព្រមព្រៀងផ្អែកតាមបញ្ញត្តិនៃមាត្រា ៩៧៩ នៃក្រមរ/ដ ( មាត្រា ៣ និង ចំណុច ៥ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃ**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**)

NO

"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (ករណីដែលមានកូនជាអនីតិជន) (សាលក្រម) "

បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃចំណុចនីមួយៗ កថា/ទី ១ មាត្រា ៩៧៨ នៃក្រមរ/ដ (ចំណុច គ មាត្រា ៣ និង កថា/ទី ១ មាត្រា ២២ នៃ**ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** )

NO

"មិនចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ! !"

ការលែងលះ គឺជានីតិវិធីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (យោងវាក្យខណ្ឌទី ២ មាត្រា ៩៧៩ នៃក្រមរ/ដ)។
អាពាហ៍ពិពាហ៍ នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរ/ដ)។ ពោលគឺ ប្រសិនបើមិនបានបញ្ចប់ឲ្យសព្វគ្រប់នូវការចុះបញ្ជីអាពាហ៍ពិពាហ៍ទេ អានុភាពនៃអាពាហ៍ពិពាហ៍នឹងមិនកើតមានឡើងទេ។
ក្នុងករណីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺពុំចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ!
ប៉ុន្តែ បុគ្គលដែលបានបដិសេធចោលដោយមិនត្រឹមត្រូវនូវ "ទំនាក់ទំនងអនីតិសង្វាស" ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយមូលហេតុនៃអំពើអនីត្យានុកូល ចំពោះភាគីម្ខាងទៀត។ ថាតើជា "ទំនាក់ទំនងអនីតិសង្វាស" ឬយ៉ាងណានោះ ត្រូវវិនិច្ឆ័យទៅលើ ទាំងឆន្ទៈរបស់គូភាគី និង ទៅលើស្ថានភាពជីវភាពជាក់ស្តែង។

# តារាងលំហូរនៃនីតិវិធីលែងលះ

បានចុះបញ្ជីអាពាហ៍ពិពាហ៍

<u>ករណីដែលមានកូនជាអនីតិជន</u>

**ជាគោលការណ៍៖ ម្ដាយ គឺជាអ្នកមានអំណាចមេបា (កថាខណ្ឌទី ១ មាត្រា ១០៣៨ នៃក្រមរ/ដ)**

ករណីលើកលែង៖ ករណីដែលឪពុកទទួលស្គាល់កូននោះ (※) និង ការពិភាក្សារបស់ឪពុកម្ដាយបានកំណត់យកឪពុកជាអ្នកមានអំណាចមេបា នោះឪពុកជាអ្នកមានអំណាចមេបា (កថាខណ្ឌទី ២ មាត្រា ១០៣៨ នៃក្រមរ/ដ)។

※ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៩៧ នៃក្រមរ/ដ)។ ព្រមទាំងករណីដែលបានចុះហត្ថលេខា ឬ ផ្ដិតមេដៃនៅក្នុងសៀវភៅកំណើតថាឈ្មោះខ្លួនជាឪពុក ត្រូវចាត់ទុកថាបានទទួលស្គាល់ (មាត្រា ៩៩៨ នៃក្រមរ/ដ)។

**<u>អ្នកមានអំណាចមេបា កំណត់ដោយយកនរណាម្នាក់រវាងម្ដាយឬឪពុកតាំងពីដើម។ នៅពេលពីរនាក់បែកគ្នា ពុំចាំបាច់កំណត់អ្នកមានអំណាចមេបាជាថ្មីម្ដងទៀតទេ។</u>**

ករណីដែលចង់ផ្លាស់ប្ដូរអ្នកមានអំណាចមេបា ត្រូវដាក់ពាក្យសុំនីតិវិធីដើម្បីផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា (មាត្រា ១០៣៩ នៃក្រមរ/ដ, មាត្រា ៣ និង ចំណុច ១២ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

NO

<u>"មិនចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ ! !"</u>

ការលែងលះ គឺជានីតិវិធីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (យោងវាក្យខណ្ឌទី ២ មាត្រា ៩៧៩ នៃក្រមរ/ដ)។
អាពាហ៍ពិពាហ៍ នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរ/ដ)។ ពោលគឺ ប្រសិនបើមិនបានបញ្ចប់ឲ្យសព្វគ្រប់នូវការចុះបញ្ជីអាពាហ៍ពិពាហ៍ទេ អានុភាពនៃអាពាហ៍ពិពាហ៍នឹងមិនកើតមានឡើងទេ។
ក្នុងករណីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺពុំចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ!
ប៉ុន្តែ បុគ្គលដែលបានបដិសេធចោលដោយមិនត្រឹមត្រូវនូវ "ទំនាក់ទំនងអនីតិសង្វាស" ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយមូលហេតុនៃអំពើអនីត្យានុកូលចំពោះភាគីម្ខាងទៀត។ ថាតើជា "ទំនាក់ទំនងអនីតិសង្វាស" ឬយ៉ាងណានោះ ត្រូវវិនិច្ឆ័យទៅលើ ទាំងឆន្ទៈរបស់គូភាគី និង ទៅលើស្ថានភាពជីវភាពជាក់ស្ដែង។

# ករណីមានវិវាទលើទ្រព្យសម្បត្តិ




ដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង។ ព្រមទាំងដាក់ពាក្យសុំបែងចែកទ្រព្យសម្បត្តិ ផ្អែកតាមមាត្រា ៣ និង ចំណុច ៦ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃ**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។**

ដាក់បណ្តឹងទាមទារលែងលះគ្នា។ ព្រមទាំងដាក់ពាក្យសុំចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ផ្អែកតាមកថា/ទី ១ មាត្រា ២២ នៃ**ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។**

ដោយសារតែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ហេតុនេះនាំឲ្យមិនមានទ្រព្យសម្បត្តិរួមដែលកំណត់នៅក្នុងមាត្រា ៩៧៣ នៃក្រមរ/ដទេ។ ទ្រព្យសម្បត្តិដែលមានកម្មសិទ្ធិតែម្ខាង គឺជាទ្រព្យសម្បត្តិដែលបុគ្គលនោះមានកម្មសិទ្ធិ។ ពុំចាំបាច់បែងចែកទ្រព្យសម្បត្តិទេ។
បន្ទាប់ពីបានកំណត់ទ្រព្យសម្បត្តិដែលមានវិវាទ សូមពិចារណាលើការដាក់បណ្តឹងរដ្ឋប្បវេណី ដើម្បីដោះស្រាយវិវាទនោះ។